

រយៈពេល២៥ឆ្នាំបានកន្លងផុតទៅហើយ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស។ សន្តិភាពនៅតែមានភាពផុយស្រួយនៅឡើយនៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាអ្នកទទួលផលប្រយោជន៍ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសម្នាក់ និងក្នុងនាមជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំសូមធ្វើការបញ្ជាក់ និងគាំទ្រអំពីការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងការចូលរួមរបស់មជ្ឈមណ្ឌលនេះ ចំពោះដំណើរការនៃការព្យាយាមសម្រេចឱ្យបាននូវសន្តិភាព។ សន្តិភាពនៅតែជាផ្លូវដ៏វែងឆ្ងាយសម្រាប់ប្រជាជនកម្ពុជា ប្រសិនបើយើងមិនដើររួមគ្នាទេនោះ។

-ឆាំង យុ

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានខិតខំប្រឹងប្រែងក្នុងការកសាងការចងចាំ ការផ្សះផ្សា និងសន្តិភាព ហើយមជ្ឈមណ្ឌលអាចសម្រេចគោលដៅទាំងនេះបានតាមរយៈការសិក្សាអំពីសន្តិភាព និងការអប់រំពីអំពើប្រល័យពូជសាសន៍។ ការសិក្សាអំពីសន្តិភាព បង្ហាញពីការព្យាយាមរបស់មជ្ឈមណ្ឌលក្នុងការកត់សម្គាល់ និងវិភាគអំពីអាកប្បកិរិយាហិង្សា និងអហិង្សា ក៏ដូចជាយន្តការបែបប្រព័ន្ធដែលបង្កឱ្យជម្លោះផ្ទុះឡើង។ ចំណែកឯការអប់រំពីអំពើប្រល័យពូជសាសន៍វិញបានតំណាងឲ្យការព្យាយាមរបស់មជ្ឈមណ្ឌល ក្នុងការរៀបរៀងកម្មវិធីសិក្សា ដែលពិភាក្សាអំពីសំណួរមូលដ្ឋានដែលសួរថា តើនៅសម័យខ្មែរក្រហមមានរឿងអ្វីកើតឡើងខ្លះ ហើយហេតុអ្វីបានជារឿងទាំងនោះកើតឡើង។ វិធីសាស្ត្រក្នុងការអប់រំទាំងពីរនេះត្រូវបានអនុវត្តជាមួយនឹងទស្សនៈដែលជំរុញឲ្យមានសន្តិភាព ការអប់រំ និងនីតិរដ្ឋ។

ទីស្នាក់ការថ្មីរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងស្ថិតនៅស្រុកអន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម។ មជ្ឈមណ្ឌល មានគោលបំណងផ្សះផ្សាការបែកបាក់រវាងអតីតកម្មាភិបាលខ្មែរក្រហម និងយុវជនកម្ពុជាជំនាន់ក្រោយ តាមរយៈការធ្វើការយ៉ាងជិតស្និតជាមួយសហគមន៍ក្នុងតំបន់ សាលារៀន និងមន្ត្រីទេសចរណ៍នានា។ គោលបំណងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះ គឺជាការផ្តល់នូវកម្មវិធីទាក់ទងនឹងការអប់រំក៏ដូចជាទេសចរណ៍ជាច្រើនដែលជួយថែរក្សាទុករឿងរ៉ាវ វត្ថុ និងទីតាំងប្រវត្តិសាស្ត្រនៅក្នុងតំបន់ ព្រមទាំងកសាងសន្តិភាព និងការផ្សះផ្សារវាងមនុស្សគ្រប់ជំនាន់ និងវណ្ណៈសង្គម។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មិនត្រឹមតែមានគោលដៅក្នុងការផ្តល់ការយល់ដឹងស៊ីជម្រៅអំពីប្រវត្តិសាស្ត្រហិង្សារបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ មជ្ឈមណ្ឌលថែមទាំងមានបំណងផ្សព្វផ្សាយការយល់ដឹងស្តីពីទ្រឹស្តីនានាទាក់ទងនឹងការដោះស្រាយនិងប្រែក្លាយជម្លោះទៀតផង។ ដោយប្រើប្រាស់ទីស្នាក់ការថ្មីនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងសម្រេចគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីនានានៅពេលអនាគតដែលផ្តោតសំខាន់ទៅលើការពិភាក្សា ការធ្វើទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់រឿងរ៉ាវផ្ទាល់ខ្លួនដើម្បីបង្ហាញពីអត្ថន័យអប់រំ និងអត្ថន័យប្រវត្តិសាស្ត្រ។ ការធ្វើទស្សនកិច្ចនឹងជួយឲ្យជនរងគ្រោះ ក៏ដូចជាអតីតកម្មាភិបាលខ្មែរក្រហមទទួលការសះស្បើយផ្លូវអារម្មណ៍ ព្រោះថា ទស្សនកិច្ចទាំងនោះនឹងផ្តល់ឱកាសឲ្យជនរងគ្រោះ និងអតីតកម្មាភិបាល ធ្វើការឆ្លុះបញ្ចាំងព្រមទាំងបញ្ចេញទស្សនៈ យល់ឃើញអំពីបទពិសោធន៍របស់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងសម័យសង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) ដែលកើតឡើងបន្តបន្ទាប់។

តាមរយៈការពិភាក្សាទល់មុខគ្នាជាមួយនឹងជនរងគ្រោះ ក៏ដូចជាអតីតកម្មាភិបាលខ្មែរក្រហម កម្មវិធីនេះនឹងជំរុញឱ្យសិក្ខាកាមគិតពិចារណាអំពីភាពទីទៃពីគ្នានៃបទពិសោធន៍របស់មនុស្ស (ទាំងក្នុងឧទាហរណ៍នៃភាពមានមនុស្សធម៌និងភាពអមនុស្សធម៌)នៅក្នុងសម័យកាលនៃជម្លោះនិងចលាចលសង្គម។ រឿងរ៉ាវទាំងនោះបញ្ជាក់អំពីសារសំខាន់នៃមនុស្សម្នាក់ៗ និងជួយជំរុញឱ្យមនុស្សម្នាក់ៗមានមូលដ្ឋានក្នុងការប្រែក្លាយជម្លោះ និងជំនាញពលរដ្ឋ។ គំនិតដូចជា សមត្ថភាពនៃការឆ្លុះបញ្ចាំងការគិតស៊ីជម្រៅ និងការយល់ពីអ្នកដទៃ គឺជាមូលដ្ឋានគ្រឹះសម្រាប់សង្គមប្រជាធិបតេយ្យដែលប្រកបដោយសុខសន្តិភាពទាំងឡាយ។ គម្រោងនេះ ផ្តោតទៅលើប្រវត្តិសាស្ត្រដែលផ្តល់ភាពអាណិតអាសូរដល់គ្នាទៅវិញទៅមក ហើយសិស្សានុសិស្ស គ្រូបង្រៀន និងមគ្គុទ្ទេសក៍ទេសចរណ៍ដែលចូលរួមក្នុងកម្មវិធីនេះ នឹងមានតួនាទីជាអ្នកតំណាងនៅសហគមន៍របស់ខ្លួនក្នុងការចែករំលែកចំណេះដឹង និងការយល់ដឹងរបស់ខ្លួន។

ការបង្កើតមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅស្រុកអន្លង់វែង តំណាងឱ្យការចាប់ផ្តើមនៃការងាររបស់មជ្ឈមណ្ឌលដែលឆ្ពោះទៅកាន់ការពង្រឹងគោលដៅនៃការកសាងសន្តិភាព ការអប់រំ និងទេសចរណ៍ប្រកបដោយនិរន្តរភាព។ តាមរយៈគោលដៅស្នូលទាំងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបាននិងកំពុងក្លាយទៅជា ស្ថាប័នឈានមុខ សម្រាប់ការអភិវឌ្ឍន៍វិធីសាស្ត្រប្រកបដោយនិរន្តភាពដើម្បីសម្រេចបាននូវការផ្សះផ្សា និងសន្តិភាពក្នុងតំបន់ក៏ដូចជាក្នុងប្រទេសកម្ពុជាទាំងមូល។

២០១៧

ជំនួយពីពលរដ្ឋអាមេរិក

9 789924 907817

ក្របមុខ៖ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍របស់គណៈមជ្ឈិម នៃបក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ១៩៧៥-១៩៧៩។ ឈរបែរទៅមុខពីខាងឆ្វេងមាន ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ) អៀង សារី (ឧបនាយករដ្ឋមន្ត្រីការបរទេស) សុន សេន (ឧបនាយករដ្ឋមន្ត្រីការពារជាតិ) វ៉ន វេត (ឧបនាយករដ្ឋមន្ត្រីសេដ្ឋកិច្ច)។ អ្នកទាំងនោះកំពុងរង់ចាំទទួលគណៈប្រតិភូចិននៅអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង។ ប្រភពព័ត៌មាន: បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម | គ្រីស្តូហ្វ័រ ឌៀរីង និង បណ្ឌិត លី សុខឃាង | សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
ក្រសួងទេសចរណ៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា



# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

គ្រីស្តូហ្វ័រ ឌៀរីង និង បណ្ឌិត លី សុខឃាង
ប្រែសម្រួលជាភាសាខ្មែរ សុភ័ក្រ្ត ភាណា

# សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍